ភ្នំពេញ , ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៣

**សារាចរ លេខ ១០ ស.រ**

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

សូមគោរពជូន និង ជំរាបជូន

ព្រះអង្គម្ចាស់សម្តេចក្រុមហ្លួង និង ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ព្រះអង្គសម្តេចក្រុមហ្លួង និង ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ

នាយកអគ្គសេនាធិការកងទ័ពជាតិកម្ពុជា

អស់លោកអភិបាល ខេត្ត ក្រុង ទូទាំងប្រទេស

កម្មវត្ថុ : វិធានការចំពោះការជ្រើសរើសទ័ព នគរបាលខុសច្បាប់ និង ចំពោះសកម្មភាពរបស់ខ្មែរក្រហម ។

យោង : - សេចក្តីជូនដំណឹងរបស់សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា អំពីវិធានការពង្រឹងវិន័យក្នុងជួរនគរបាល លេខ ០៣ សជណ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៣ ។

- សារាចរស្តីពីបញ្ហាមួយចំនួនជុំវិញការតែងតាំងមន្ត្រី និយោជិក សំរាប់ក្រសួង ស្ថាប័ននិមួយ ៗ លេខ ០៤ សរ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៣ ។
- សេចក្តីប្រកាសរបស់រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជាលេខ ០២ ស.ប្រ.ក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៣ ។
- បទបញ្ជារបស់រដ្ឋាភិបាលជាតិបណ្តោះអាសន្ន ស្តីពីការណ៍ជុំវិញការឃោសនាជ្រើសរើសទ័ព នគរបាល មន្ត្រី រដ្ឋការស៊ីវិល និង ការចាត់តាំងរដ្ឋអំណាចមូលដ្ឋាន លេខ ០៨ ស.រ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣ ។

ដោយកត់សំគាល់ឃើញថា សកម្មភាពជ្រើសទ័ព នគរបាលខុសច្បាប់នៅកើតមានជាបន្តបន្ទាប់បង្កឡើងដោយជនមួយចំនួន ដែលប្រើប្រាស់នាមឋានៈបក្សនយោបាយ ឬ ផ្នែកយោធាពួកផ្សេង ៗ រហូតប្រើប្រាស់ព្រះនាមសម្តេចព្រះនរោត្តម សីហនុ ដើម្បីផលប្រយោជន៍បក្សពួក និង ផ្ទាល់ខ្លួន ។

ដោយកត់សំគាល់ឃើញថា ភាគីកម្ពុជាប្រជាធិបតេយ្យ នៅតែបន្តមិនគោរពគោលការណ៍ព្រមព្រៀងក្រុងប៉ារីស ជាពិសេសក្រោយការបោះឆ្នោត ជ្រើសរើសសភាធម្មនុញ្ញ ដែលខ្លួនបានប្រកាសទទួលស្គាល់លទ្ធផលដែរនោះ និង ក្រោយការបង្កើតរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ភាគីនេះនៅ

តែរំលោភលើបទឈប់បាញ់ ហើយបានបង្កើនសកម្មភាព វាយប្រហារភូមិសាស្ត្រ វាយទីតាំងឈរជើងរបស់កងទ័ពជាតិកម្ពុជា និងប៉ុស្តិ៍នគរបាល ផ្តាច់ផ្លូវគមនាគមន៍ បំផ្លាញស្ពាន ប្លន់ សំលាប់ បង្កការភ័យខ្លាច និង រំខានសកម្មភាពច្រើន ចំពោះប្រជារាស្ត្រស្លូតត្រង់ ព្រមទាំងក្លែងបន្លំ ខ្លួនជាកងអាវុធពីកងជីវពល និង ផ្ទុំសកម្មភាពនៅមូលដ្ឋាន និង ក្លែងបន្លំជ្រើសរើសទាហានទៀតផង ។

ដើម្បីពង្រឹងសណ្តាប់ធ្នាប់ សន្តិសុខសង្គម កុំបណ្តោយទៅលើភាពអនាធិបតេយ្យ ធានាការរស់នៅដោយសុខសាន្តជូនប្រជារាស្ត្រ រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ចេញសារាចរនេះ ដើម្បីអោយ :

- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ
- អគ្គសេនាធិការកងទ័ពជាតិកម្ពុជា
- ខេត្ត ក្រុង ទូទាំងប្រទេស

ចាត់វិធានការដូចតទៅ :

១- ធ្វើអន្តរាគមន៍ជាបន្ទាន់ បង្ក្រាបសកម្មភាពអនាធិបតេយ្យ ដូចមានចែងខាងលើ ជាពិសេសការជ្រើសរើសទ័ព និង នគរបាលខុសច្បាប់ ។ កងទ័ព និង នគរបាល ដែលបានជ្រើសរើស ដោយ ខុសច្បាប់កន្លងមក ត្រូវធ្វើការរំលាយជាបន្ទាន់ ។ ក្រសួងមានសមត្ថកិច្ច ត្រូវអនុវត្តម៉ឺងម៉ាត់ នូវបទបញ្ជារបស់ រ.ជ.ប.ក លេខ ០៤ ស.រ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣ ជាពិសេសត្រូវចាត់វិធានការចាប់ខ្លួនជនដែលប្រព្រឹត្តល្មើស នឹងបទបញ្ជានេះ បញ្ជូនទៅតុលាការ ។

២- លើកឡើងវិធានការ ប្រើប្រាស់អោយបានពេញនូវសិទ្ធិការពារខ្លួន ដើម្បីរក្សាបានសន្តិសុខ សណ្តាប់ធ្នាប់សង្គម ការពារអាយុជីវិត ទ្រព្យសម្បត្តិជូនប្រជារាស្ត្រ ការពារអោយបានផ្លូវគមនាគមន៍ ផ្លូវគោក ផ្លូវដែក ស្ពានថ្នល់ ផ្លូវទឹក ការពារគោលដៅសំខាន់ៗ ខាងនយោបាយ សេដ្ឋកិច្ច វប្បធម៌ និង ការពារអោយបានភូមិសាស្ត្រគ្រប់គ្រង របស់រដ្ឋាភិបាលជាតិកម្ពុជា ដែលជារដ្ឋាភិបាលប្រសូត្រចេញពីឆន្ទៈរបស់ប្រជារាស្ត្រ ។

៣- រៀបចំ និង ពង្រឹងឡើងវិញនូវប៉ុស្តិ៍នគរបាល រដ្ឋបាល ដែលធ្លាប់មានកន្លងមកទាំងអស់ និង ពង្រឹងកងជីវពលឡើងវិញអោយបានសមស្រប ។

៤- ឈរលើទស្សនៈបង្រួបបង្រួមជាតិ " ខ្មែរតែមួយ " ត្រូវសកម្មអំពាវនាវអោយបងប្អូន ដែលពីមុននេះជាសមាជិករបស់គណបក្សនយោបាយនានា ហើយមានការភ័យខ្លាចរត់ចេញពីមូលដ្ឋាន ទោះជាទៅរស់នៅក្នុងមជ្ឈដ្ឋានណាក៏ដោយ រាប់បញ្ចូលទាំងកំលាំងរបស់ខ្មែរក្រហមផង អោយវិល

ត្រឡប់មកវិញ ។ ឯរង្វាន់គ្រប់ថ្នាក់ត្រូវមានវិធានការផ្តល់សន្តិសុខគ្រប់គ្រាន់ដល់បងប្អូន ដែលវិល ត្រឡប់មកវិញទាំងនោះ ។

ទទួលបានសារាចរនេះ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ អគ្គសេនាធិការកងទ័ពជាតិ អភិបាលខេត្ត ក្រុង ទាំងអស់ ត្រូវខិតខំអនុវត្តន៍អោយមានប្រសិទ្ធភាពខ្ពស់ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមហ្លួន នរោត្តម រណឫទ្ធិ ហ៊ុន សែន

## ៤ - ប្រកាស

ធ្វើនៅភ្នំពេញ , ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៣

### សេចក្តីប្រកាស លេខ ០៣ សប្រក

នៃរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

x x x

ដោយសង្កេតឃើញថា ក្នុងរយៈពេលចុងក្រោយនេះ ជាពិសេសក្នុងរយៈពេលមុននិងក្រោយ បោះឆ្នោត បានមានភាព អនាធិបតេយ្យ ក្នុងការកាន់កាប់ដី ដីកសម្បត្តិ នាំចេញឈើ និងក្នុងការ កាប់ និង ចាក់ ដើមឈើដោយខុសច្បាប់ ក្នុងនេះមានការលួចកាប់ដើមឈើ ការលួចទៀតផង ឬការ ទាក់ទងអោយប្រជារាស្ត្រ ឬ កម្មករកាប់ឈើ ជៀសវាងជំរ បំពានលើទង្វើបង្កការ ដើម្បីលក់ អោយ ក្រុមខ្លួន បានកើនឡើងយ៉ាងខ្លាំងក្លា ជាងពេលណា ៗ ទាំងអស់ ដែលបង្កឡើងដោយ ជនមួយចំនួន ក្នុង នេះមានពួកល្មើសច្បាប់ ដែលអាងមីកញ្ញាក់ អាងអាវុធ គិតតែផលប្រយោជន៍ ផ្ទាល់ខ្លួន បំពានលើ ច្បាប់ ភ្លេចគិតដល់ផលប្រយោជន៍ជាតិ ភ្លេចគិតដល់ធនធានធម្មជាតិរបស់ខ្លួន ។ សកម្មភាពទាំងនេះ បានបង្កើតជាវិបត្តិមួយ យ៉ាងធ្ងន់ធ្ងរចំពោះការរស់នៅ សេដ្ឋកិច្ច សណ្តាប់ធ្នាប់ សង្គមយ៉ាងជ្រាលជ្រៅ នាំ អោយខូចខាតដល់ធនធានព្រៃឈើយ៉ាងច្រើន ដែលទាមទារអោយរដ្ឋាភិបាល មានវិធានការជាបន្ទាន់ ដើម្បី ទប់ស្កាត់ដោយម៉ឺងម៉ាត់បំផុត ។